ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៤
## និងទិសដៅការងារឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា
### នៅធនាគារជាតិនៃកម្ពុជា, ថ្ងៃទី៩-១០ ខែកុម្ភៈ ឆ្នាំ២០១៥

សូមគោរព ៖

- គណៈអធិបតី
- លោក Hervé DALLERAC ជំនាញការទូទៅប្រចាំធនាគារជាតិនៃកម្ពុជា
- លោក Robert Beerens ជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ក្នុងឱកាសសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា នាពេលនេះ។ ជារៀងរាល់ឆ្នាំ យើងតែងតែរៀបចំសន្និបាតបូកសរុបលទ្ធផលការងារ ដើម្បីផ្សព្វផ្សាយនិងអបអរសាទរលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជា បានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល និងបណ្តាសាខានៅរាជធានី-ខេត្ត បានជួបពិភាក្សាផ្លាស់ប្តូរបទពិសោធន៍គ្នា និងពង្រឹងកិច្ចសហប្រតិបត្តិការជាបណ្តាញការងារ សំដៅរួមចំណែកអនុវត្តទិសដៅការងារថ្មីតាមភារកិច្ចរៀងខ្លួន ឱ្យសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិកនៅទីស្នាក់ការធនាគារជាតិនៃកម្ពុជា ដែលបានអញ្ជើញចូលរួមនៅពេលនេះ និងធ្វើបទអន្តរាគមន៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។ ខ្ញុំសូមថ្លែងកោតសរសើរយ៉ាងខ្លាំងផងដែរ ចំពោះមន្ត្រីបុគ្គលិកគ្រប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់និងសម្រេចបានសមិទ្ធផលជាបន្តបន្ទាប់ ជូនធនាគារជាតិនៃកម្ពុជា ជាពិសេសបានរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យរីកចម្រើន និងមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោក ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- គណៈអធិបតី
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

អង្គសន្និបាតយើងថ្ងៃនេះ ត្រូវបានរៀបចំឡើងក្រោមបរិយាកាសសប្បាយរីករាយបំផុតបន្ទាប់ពីប្រជាជនកម្ពុជានៅទូទាំងប្រទេស បានប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩ - ៧ មករា ២០១៥ ហើយក៏ជាឆ្នាំដែលក្រុមប្រទេសអាស៊ានទាំង១០ ចាប់ផ្តើមដំណើរការសមាគមសេដ្ឋកិច្ចរបស់ខ្លួនដែរ ។ ការរៀបចំសន្និបាតរបស់យើងឆ្នាំនេះ គឺដើម្បីផ្សព្វផ្សាយពីលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងឆ្នាំ២០១៤ ដូចខាងក្រោម ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៤

កាលពីឆ្នាំ២០១៤ សេដ្ឋកិច្ចសកលបានបន្តងើបឡើងជាវិជ្ជមាន ក្នុងអត្រាកំណើន ៣,៣% ស្មើនឹងឆ្នាំមុន ទោះបីជាមានល្បឿនយឺតជាងការរំពឹង ហើយមានលក្ខណៈមិនស្មើសាច់ និងផុយស្រួយនៅឡើយ ដោយហានិភ័យមួយចំនួនអាចប៉ះពាល់ដល់ទស្សនវិស័យកំណើន ។ កំណើននៃប្រទេសអភិវឌ្ឍកាន់តែងើបឡើងជាបណ្តើរៗ ខណៈដែលកំណើនរបស់ប្រទេសកំពុងអភិវឌ្ឍន៍មានសន្ទុះថយចុះ ។

កំណើនសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍន៍ ដូចជាសហរដ្ឋអាមេរិក មានស្ថានភាពរឹងមាំ ប៉ុន្តែប្រទេសជប៉ុនបានទទួលរងឥទ្ធិពលនៃការតម្លើងពន្ធលើការប្រើប្រាស់ ហើយតំបន់អឺរ៉ូកំពុងជួបហានិភ័យបរិត្តជរណានិងភាពទ្រឹងនៃសេដ្ឋកិច្ច ។ ចំពោះប្រទេសកំពុងងើបឡើង និងកំពុងអភិវឌ្ឍន៍វិញ កំណើនត្រូវបានគាំទ្រដោយតម្រូវការក្នុងស្រុកនិងការងើបឡើងនៃសេដ្ឋកិច្ចសកល ។ ចំពោះកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន បានថយចុះដល់កម្រិតទាបជាងមុនចាប់តាំងពីឆ្នាំ២០១១ មក ដោយសារឥទ្ធិពលអន្តរកាលនៃកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយកំណើនសេដ្ឋកិច្ចអាស៊ាន-៥ ក៏ត្រូវបានថមថយបន្តិច ដោយសារការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចប្រទេសថៃនិងឥណ្ឌូនេស៊ី ។

ចំណែកឯសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានបន្តអភិវឌ្ឍយ៉ាងឆាប់រហ័សប្រកបដោយភាពរឹងមាំ ទោះបីជាសេដ្ឋកិច្ចសកលនៅមិនទាន់មានភាពរឹងមាំក៏ដោយ ។ នៅឆ្នាំ២០១៤ សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ក្នុងអត្រាប្រមាណ ៧% ហើយផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (GDP per capita) បានកើនដល់ ១.១៥៨ ដុល្លារអាមេរិក ។ ការរក្សាបាននូវអត្រាកំណើននេះ ដោយសារភាពអំណោយផលពីការកើនឡើងនៃវិស័យសំណង់ ឧស្សាហកម្មកាត់ដេរ វិស័យទេសចរណ៍ និងកសិកម្ម ។ អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយនៅក្រោម ១៨% ដោយក្នុង ១ ឆ្នាំអត្រាភាព

ក្រីក្រថយជាង ១% ចំណែកឯអត្រាអតិផរណាស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបាន ហើយអត្រាប្តូរប្រាក់និងថ្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានស្ថិរភាព ។ ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចបន្តមានស្ថិរភាពល្អប្រសើរ ។ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបន្តអនុវត្តកម្មវិធីកំណែទម្រង់សំខាន់នានា ។

## II/- សមិទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆ្នាំ២០១៤ កន្លងមក

នៅឆ្នាំ២០១៤ កន្លងមក ធនាគារជាតិនៃកម្ពុជាខិតខំរក្សាបាននូវស្ថិរភាពថ្លៃតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ននិងទន់ភ្លន់ ។ ជាក់ស្តែង អត្រាអតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាបប្រមាណ ៣% និងតម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរដោយអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក បានប្រែប្រួលបន្តិចបន្តួចជាមធ្យមក្នុងរង្វង់ ៤.០០០ រៀល ក្នុង១ដុល្លារអាមេរិក។ ក្រៅពីនេះ យើងបានខិតខំលើកកម្ពស់និងអភិវឌ្ឍគោលនយោបាយនៃការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។ ចំណែកឯការគ្រប់គ្រងទុនបម្រុងអន្តរជាតិវិញ ត្រូវបានអនុវត្តតាមគោលការណ៍ប្រុងប្រយ័ត្ន គឺរក្សាបានសុវត្ថិភាព សន្ទនីយភាព និងចំណូល ។ បច្ចុប្បន្ន បរិមាណទុនបម្រុងអន្តរជាតិរបស់យើងបានបន្តកើនឡើងជាលំដាប់ ដែលអាចធានាការនាំចូលបានប្រមាណជាង ៤ ខែ ។ គោលបំណងសំខាន់នៃការរក្សាទុនបម្រុងអន្តរជាតិ គឺដើម្បីពង្រឹងរបបអត្រាប្តូរប្រាក់ ស្ថានភាពជញ្ជីងទូទាត់ ស្ថិរភាពវិស័យហិរញ្ញវត្ថុ ជំនឿទុកចិត្តរបស់សាធារណជន ប្រភពចំណូល និងជាឃ្លាំងដើម្បីពូនគរទ្រព្យសម្បត្តិជាតិ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរដូចខាងក្រោម៖

**១/-វិស័យធនាគារ** : បច្ចុប្បន្ន វិស័យធនាគារបាននិងកំពុងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ក្នុងការកៀរគរនិងបែងចែកមូលនិធិសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ដោយបំពេញបន្ថែមដើមទុនទៅឱ្យសហគ្រាស ក្រុមហ៊ុន ឬអាជីវកម្មខ្នាតតូច សម្រាប់គម្រោងវិនិយោគនិងពង្រីកផលិតកម្មរបស់ខ្លួន ។ ចំណែកឯទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារបានកើនឡើងដល់ ១៥ពាន់លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ១០០% នៃផ.ស.ស ខណៈដែលប្រាក់បញ្ញើបានកើនឡើងដល់ ៩ ពាន់លានដុល្លារ និងឥណទានចំពោះវិស័យឯកជនបានកើនឡើងដល់ ៨ ពាន់លានដុល្លារអាមេរិក ។ ជាក់ស្តែង ប្រជាជនអាយុលើស១៥ឆ្នាំ មានប្រមាណ ៤២% ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ធៀបនឹង ១៩% កាលពី ៥ឆ្នាំមុន ។ ប្រតិបត្តិការនិងសាខារបស់គ្រឹះស្ថានធនាគារត្រូវបានពង្រីកឥតឈប់ឈររហូតដល់ ៥៤២ សាខា ព្រមទាំងមានម៉ាស៊ីន

ដកប្រាក់ស្វ័យប្រវត្តិ (ATM) ជាង ៩០០ កន្លែងនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដើម្បីសម្រួលដល់ការដក ដាក់ និងផ្ទេរប្រាក់របស់ប្រជាពលរដ្ឋ ។

ចំណែកឯប្រព័ន្ធទូទាត់ជាតិដែលជាស្នូលនៃហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ ក៏ត្រូវបានអភិវឌ្ឍជាលំដាប់ ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់ដុំ និងរាយដែលកើនឡើងឥតឈប់ឈរទៅតាមការរីកចម្រើននៃសេដ្ឋកិច្ច និងឆ្លើយតបនឹងការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុអាស៊ាន ។ ការអភិវឌ្ឍប្រព័ន្ធទូទាត់នឹងសម្រួលដល់ប្រតិបត្តិការទូទាត់ឱ្យមានសុវត្ថិភាព ប្រសិទ្ធភាព ទំនុកចិត្ត និងកាត់បន្ថយចំណាយប្រតិបត្តិការ ។ ក្រៅពីនេះ យើងកំពុងអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ តាមរយៈការជំរុញការប្រើប្រាស់និងជួញដូរមូលបត្រអាចជួញដូរបាន (NCDs) ឱ្យកាន់តែទូលំទូលាយ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ ដើម្បីពង្រីកលទ្ធភាពផ្គត់ផ្គង់សន្ទនីយភាព និងបង្កើតឧបករណ៍បន្ថែមសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព ។

**២/- ការងារត្រួតពិនិត្យធនាគារ** : ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានពង្រឹងសុខភាពប្រព័ន្ធធនាគារ តាមរយៈការពង្រឹងការត្រួតពិនិត្យដល់ទីកន្លែងនិងការត្រួតពិនិត្យលើឯកសារ ទាំងក្នុងក្របខ័ណ្ឌមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្ន ហើយវិធីសាស្ត្រត្រួតពិនិត្យត្រូវបានធ្វើឡើងដោយផ្អែកលើហានិភ័យនិងទស្សនវិស័យអនាគត ដោយប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យលើឯកសារ ។ ចំពោះក្របខ័ណ្ឌបទប្បញ្ញត្តិវិញ បទប្បញ្ញត្តិមួយចំនួនត្រូវបានពិនិត្យនិងកែសម្រួលឱ្យសមស្របតាមស្ថានភាពនិងទំហំប្រតិបត្តិការ រួចដាក់ឱ្យអនុវត្តស្របតាមការរីកចម្រើននៃវិស័យធនាគារនៅកម្ពុជា ការប្រែប្រួលនៃនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ និងការអនុវត្តល្អជាអន្តរជាតិផងដែរ ។

ក្របខ័ណ្ឌនៃទីផ្សាររូបិយវត្ថុ ទីផ្សារអន្តរធនាគារ និងទីផ្សារប្តូរប្រាក់កំពុងត្រូវបានអភិវឌ្ឍ ហើយធនាគារជាតិនៃកម្ពុជា ក៏បានបោះផ្សាយមូលបត្រអាចជួញដូរបាន (NCD) និងបានសិក្សាលើការអភិវឌ្ឍទីផ្សារប្តូរប្រាក់ដុំនៅកម្ពុជា ដើម្បីលើកកម្ពស់ការគ្រប់គ្រងហានិភ័យសន្ទនីយភាព និងហានិភ័យប្តូរប្រាក់ឱ្យកាន់តែប្រសើរឡើង ។

**៣/- វិស័យមីក្រូហិរញ្ញវត្ថុ** : វិស័យនេះ មានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំង មានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ។ វិស័យនេះ បន្តរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូច ជូនប្រជាជននិងសហគ្រាសធុនតូចនិងមធ្យម នៅទូទាំងប្រទេស ជាពិសេសនៅតំបន់ជនបទ ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។ ក្នុងអំឡុងពេលមួយទស្សវត្សនេះ ទ្រព្យសកម្មវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ពី ១% ដល់១៤% នៃផ.ស.ស ។

ជាក់ស្តែង ឥណទានដែលបានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានបន្តកើនឡើងគួរឱ្យកត់សម្គាល់ ។ ប្រជាជនជនបទបានទទួលសេវាហិរញ្ញវត្ថុក្នុងតម្លៃសមស្របសម្រាប់យកទៅប្រកបអាជីវកម្មរបស់ខ្លួន ។ ភាពជឿនលឿននេះ បង្ហាញពីការរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ហើយក៏បានបញ្ជាក់ឱ្យឃើញអំពីការយល់ដឹងកាន់តែប្រសើរឡើងរបស់ប្រជាពលរដ្ឋកម្ពុជាពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទានផងដែរ ។

**៤/- ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** : មានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងក្នុងក្របខ័ណ្ឌជាតិនិងក្របខ័ណ្ឌសហប្រតិបត្តិការអន្តរជាតិ ។ នៅក្នុងក្របខ័ណ្ឌជាតិ យើងបានរៀបចំបង្កើតក្របខ័ណ្ឌច្បាប់ គឺអនុក្រឹត្យស្តីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករនិងអង្គការនានា និងដាក់ចេញនូវយន្តការអនុវត្តច្បាប់ជាមួយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។ ក្រៅពីនេះ យើងបានបន្តសហការជាមួយប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍ដូចជាធនាគារអភិវឌ្ឍអាស៊ី ដើម្បីរៀបចំឯកសារវិធីសាស្ត្រ សេចក្តីណែនាំ និងនីតិវិធីវាយតម្លៃហានិភ័យ និងជាពិសេស បានចូលរួមជាមួយសមាគមជាតិនិងអន្តរជាតិ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**៥/- ការពង្រឹងអភិបាលកិច្ចល្អ** : ដើម្បីពង្រឹងសុវត្ថិភាពប្រតិបត្តិការធនាគារកណ្តាល ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចជាប់ជាប្រចាំ។ នៅឆ្នាំ២០១៤នេះ មន្ត្រីជំនាញនៃអគ្គាធិការដ្ឋានយើងបានចុះធ្វើសវនកម្មការងារវិនិយោគទុនបម្រុងអន្តរជាតិ នៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ការងារដឹកជញ្ជូនសាច់ប្រាក់នៅនាយកដ្ឋាន បោះផ្សាយនិងឃ្លាំងបេឡា និងការងារប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជា ចំនួន ៥ គឺ សាខាខេត្តស្វាយរៀង តាកែវ កំពត ព្រះសីហនុ និងខេត្តបាត់ដំបង ព្រមទាំងបានចុះតាមដានការអនុវត្តតាមនូវអនុសាសន៍កែលម្អ ដែលបានដាក់ចេញកាលពីឆ្នាំ២០១៣ ដើម្បីពង្រឹងប្រសិទ្ធភាពប្រតិបត្តិការធនាគារកណ្តាល និងកាត់បន្ថយហានិភ័យផងដែរ ។

ចំពោះការងារអធិការកិច្ចវិញ បានអនុវត្តចំពោះសាខាធនាគារជាតិនៃកម្ពុជា បានចំនួន ១៤ ដោយផ្តោតទៅលើការងារគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តតាមសេចក្តីណែនាំនានារបស់ធនាគារជាតិនៃកម្ពុជា រួមទាំងការពង្រឹងវិន័យការងាររបស់មន្ត្រីបុគ្គលិក ដើម្បីពង្រឹងការគ្រប់គ្រងនិងកិច្ចដំណើរការការងារឱ្យប្រព្រឹត្តទៅកាន់តែប្រសើរឡើង។

**៦/- ការអភិវឌ្ឍប្រព័ន្ធជាត់ទាត់ជាតិ** : ដើម្បីគ្រប់គ្រងប្រតិបត្តិការនិងដឹកនាំការងារនេះ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា បានសម្រេចបង្កើតនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ ហើយថ្នាក់ដឹកនាំបានរៀបចំចាត់តាំងម៉ាស៊ីនថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៅក្នុង

នាយកដ្ឋាននេះផងដែរ ដើម្បីជាកិច្ចដំណើរការ ។ ចំពោះការអភិវឌ្ឍន៍ប្រព័ន្ធ Shared Switch យើងកំពុងពង្រឹងកិច្ចដំណើរការនិងប្រសិទ្ធភាពនៃការទូទាត់តាម ATM របស់អន្តរធនាគារ និងការទូទាត់តាមទូរស័ព្ទចល័ត និងអ៊ីនធើណែត ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ តម្លៃរាយ ដើម្បីជំរុញការប្រើប្រាស់ការទូទាត់សងប្រាក់អេឡិចត្រូនិកនៅទូទាំងប្រទេស ឱ្យមានប្រសិទ្ធភាពនិងសុវត្ថិភាពខ្ពស់។ ក្រៅពីនេះ យើងបាននិងកំពុងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិសំខាន់ៗសម្រាប់គ្រប់គ្រងប្រព័ន្ធទូទាត់ និងបានចូលរួមប្រឹក្សាផ្តល់យោបល់លើការរៀបចំបញ្ចូលខ្លឹមសារដែលពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពី អ៊ី-ពាណិជ្ជកម្ម ផងដែរ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ជាគោលនយោបាយផង និងជាយន្តការការងារផង ហើយក៏ជាការងារអាទិភាពក្នុងការលើកកម្ពស់និងការជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយផងដែរ ។ សាខាធនាគារជាតិនៃកម្ពុជា មានតួនាទីសម្របសម្រួល និងដាក់ឱ្យចរាចរសាច់ប្រាក់នៅទូទាំងប្រទេស ព្រមទាំងដើរតួនាទីជាអ្នកប្រមូលក្រដាសប្រាក់ទក់ រហែក ចាស់សឹករិចរឹល ដើម្បីដាក់ជំនួសក្រដាសប្រាក់ថ្មីក្នុងចរាចរវិញ ។ យើងក៏បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី៣ របស់រាជរដ្ឋាភិបាលផងដែរ ។

**៨/- ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិវិញ** : នៅឆ្នាំ២០១៤ ធនាគារជាតិនៃកម្ពុជា មានកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងៗ ដូចជា ៖

**ជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** : ក្នុងឆ្នាំនេះ ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជា ចំនួន ៤ លើក ។ លើកទី១ ដើម្បីជួយពង្រឹងការវិភាគស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា ។ លើកទី២ ដើម្បីជួយពង្រឹងការវិភាគលើសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ ។ លើកទី៣ ដើម្បីតាមដានស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងលើកទី៤ ដើម្បីជួយពង្រឹងស្ថិតិជញ្ជីងទូទាត់និងស្ថានភាពវិនិយោគអន្តរជាតិ តាមដានវឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើងកន្លងមក វាយតម្លៃក្របខ័ណ្ឌប្រមូលទិន្នន័យស្តីពីការវិនិយោគផ្ទាល់ពីបរទេស និងជួយក្នុងសម្រួលស្ថិតិវិស័យខាងក្រៅ ស្របតាមគោ លការណ៍ណែនាំនៅក្នុងសៀវភៅណែនាំស្តីពីជញ្ជីញទូទាត់បោះពុម្ពលើកទី៦ ។

**ជាមួយធនាគារពិភពលោក (WB) និងទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន (JICA)**: ក្រុមការងារជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក បានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន ក្នុងបំណងដើម្បីរៀបចំកែសម្រួលឱ្យស្របតាមការរីកចម្រើនរបស់វិស័យធនាគារ និងការអនុវត្តជាអន្តរជាតិ ។ ចំណែកឯ JICA

បានផ្តល់ជំនួយបច្ចេកទេស ជូនធនាគារជាតិនៃកម្ពុជាលើគម្រោងស្រាវជ្រាវស្តីពីការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដែលមានរយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៣-២០១៥ ដើម្បីសិក្សាឱ្យបាន ស៊ីជម្រៅលើស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជាព្រមទាំងការវិភាគនិងវាយតម្លៃពីវិធានការ និងគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ។

**ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី** (ADB): ធនាគារអភិវឌ្ឍន៍អាស៊ីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។ ស្ថិតក្រោមជំនួយបច្ចេកទេសរបស់ ADB រាជរដ្ឋាភិបាលបានអនុម័តបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ ប្រកបដោយជោគជ័យ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព ។

**ជាមួយមជ្ឈមណ្ឌល SEACEN** : កិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល SEACEN ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ ក្នុងក្របខ័ណ្ឌតំបន់ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ រូបិយវត្ថុ ធនាគារ និងការអភិវឌ្ឍសេដ្ឋកិច្ច ។ ធនាគារជាតិនៃកម្ពុជា ក៏បានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំនានា ព្រមទាំងចាត់តាំងមន្ត្រីជំនាញចូលរួមក្នុងគម្រោងស្រាវជ្រាវនានារបស់មជ្ឈមណ្ឌល SEACEN នៅតាមបណ្តាប្រទេសជាសមាជិក ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា ក៏បានសហការជាមួយមជ្ឈមណ្ឌលSEACEN ដើម្បីទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាចំនួនពីរផងដែរនៅខេត្តសៀមរាប ។

**កិច្ចសហប្រតិបត្តិការអាស៊ាន និងអាស៊ាន+៣**: ធនាគារជាតិនៃកម្ពុជា បានបន្តចូលរួមយ៉ាងសកម្ម ក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាននិងអាស៊ាន+៣ ។ កិច្ចសហប្រតិបត្តិការអាស៊ាន កម្ពុជាបានចូលរួមជាមួយប្រទេសជាសមាជិក ដើម្បីជំរុញដំណើរធ្វើសមាហរណកម្មផ្នែកសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (FSL) សេរីភាវូបនីយកម្មគណនីមូលធន (CAL) ការអភិវឌ្ឍទីផ្សារទុន (CMD) ការអភិវឌ្ឍប្រព័ន្ធទូទាត់អាស៊ាន (PSS) ការអភិវឌ្ឍក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន (ABIF) និងការកសាងសមត្ថភាពធនធានមនុស្ស (SCCB) នៅក្នុងតំបន់ ។

**ជាមួយធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង** (Francophone) : ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ ក្នុងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល ការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងកិច្ចសហប្រតិបត្តិការរូបិយវត្ថុ ។ នៅឆ្នាំ២០១៤ យើងបានដឹកនាំគណៈប្រតិភូទៅចូលរួមសន្និសីទប្រចាំឆ្នាំថ្នាក់ទេសាភិបាលធនាគារកណ្តាល នៃក្រុមប្រទេសនិយាយភាសាបារាំង លើកទី២១ ក្រោមប្រធានបទ ស្ថិរភាពទីផ្សារបំណុលអធិបតេយ្យ ហិរញ្ញប្បទានសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុ នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់ ។

**ជាមួយសមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA)** : ក្នុងអាណត្តិជាប្រធាន APRACA រយៈពេលពីរឆ្នាំកន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ជាមួយបណ្តាប្រទេសជាសមាជិកទាំងអស់ និងជាមួយលេខាធិការដ្ឋាន APRACA ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាអំពីគម្រោងអនុវត្តបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន និងវេទិកាថ្នាក់តំបន់ស្តីពីមីក្រូហិរញ្ញវត្ថុសម្រាប់កសិកម្ម ។

**កិច្ចសហប្រតិបត្តិការទ្វេភាគី** យើងបានពង្រឹងនិង ពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយធនាគារ កណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ឆេក លុចហ្សំបួរ អាល្លឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ាន និង អាស៊ាន+៣ លើផ្នែកបណ្តុះ-បណ្តាលធនធានមនុស្សនិងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងរៀនសូត្រពីការអនុវត្តល្អៗជាអន្តរជាតិ ។ ធនាគារជាតិនៃកម្ពុជា បានទៅចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយធនាគារកណ្តាលឡាវ ធនាគារកណ្តាលវៀតណាម និងទទួលរៀបចំកិច្ចប្រជុំជាមួយធនាគារកណ្តាលថៃ ដើម្បីពិភាក្សាផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ ទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការត្រួតពិនិត្យធនាគារ ។

ធនាគារជាតិនៃកម្ពុជា ក៏បានពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលក្នុងប្រទេសអឺរ៉ុបខាងកើតផងដែរ ដោយបានចុះអនុស្សរណៈយោគយល់ជាមួយធនាគារកណ្តាលបេឡារូស ដើម្បីជំរុញទំនាក់ទំនងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងសម្រួលដល់ការទូទាត់ រវាងប្រទេសទាំងពីរ។

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងមានសព្វថ្ងៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ របស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងការចូលរួមសហការរបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេល ពីរថ្ងៃ សូម លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារដែលអនុវត្តកន្លងមក និងអនុសាសន៍ផ្សេងៗ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួន ឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែក កសាងធនាគារជាតិនៃកម្ពុជាឱ្យទទួលបាន លទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់ យើងថ្ងៃនេះមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**!